**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
* * * * * *

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
* * * * * *

# ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន ទទួល ឯកឧត្តម Zaheeruddin Babar Thaheem ឯកអគ្គរដ្ឋទូតថ្មីនៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម

នៅព្រឹកថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២២ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអនុញ្ញាតឲ្យ **ឯកឧត្តម** Zaheeruddin Babar Thaheem ឯកអគ្គរដ្ឋទូតថ្មី នៃសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងការស្វាគមន៍ចំពោះ **ឯកឧត្តម** Zaheeruddin Babar Thaheem ដែលត្រូវបានតែងតាំងជា ឯកអគ្គរដ្ឋទូតប៉ាគីស្ថាន ប្រចាំនៅកម្ពុជា និងបានសម្តែងនូវជំនឿជាក់ថា ក្នុងអាណត្តិរបស់ ឯកឧត្តមឯកអគ្គរដ្ឋទូត ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគី នឹងត្រូវបានលើកកម្ពស់បន្ថែមទៀត ព្រមទាំងបានបញ្ជាក់អំពីការត្រៀមផ្តល់កិច្ចសហការពេញលេញរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដល់ **ឯកឧត្តម** ក្នុងការបំពេញបេសកកម្មឱ្យទទួលបានជោគជ័យ។

ជាការឆ្លើយតប **ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានគូសបញ្ជាក់ថា នឹងខិតខំធ្វើយ៉ាងណាឱ្យទំនាក់ទំនងទ្វេភាគីនឹងត្រូវបានពង្រឹង និងពង្រីកបន្ថែមទៀត ក្នុងអាណត្តិការទូតរបស់ឯកឧត្តម។ **ឯកឧត្តម** បានអបអរសាទរកម្ពុជា ចំពោះតួនាទីជាប្រធានអាស៊ាន និងបានសម្តែងក្តីសង្ឃឹមថា **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** នឹងសម្រេចបានជោគជ័យក្នុងតួនាទីជាប្រេសិតពិសេសរបស់ប្រធានអាស៊ានស្តីពីមីយ៉ាន់ម៉ា ជាពិសេស ក្នុងការស្វែងរកដំណោះស្រាយសម្រាប់វិបត្តិមីយ៉ាន់ម៉ា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានកោតសរសើរចំពោះរដ្ឋាភិបាលប៉ាគីស្ថាន ដែលបានគ្រប់គ្រងការរីករាលដាលជំងឺកូវីដ១៩ បានល្អ តាមរយៈការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋរបស់ខ្លួន ហើយ **ឯកឧត្តម** ក៏បានលើកឡើងអំពីលទ្ធផលជោគជ័យត្រចះត្រចង់នៃយុទ្ធនាការចាក់វ៉ាក់សាំងរបស់កម្ពុជា ដែលប្រជាជនប្រមាណ ៩២% នៃប្រជាជនសរុប បានចាក់វ៉ាក់សាំងរួច ហើយដែលអនុញ្ញាតឱ្យកម្ពុជាអាចបើកសកម្មភាពសង្គម-សេដ្ឋកិច្ច និងទេសចរណ៍របស់ប្រទេសឡើងវិញជាបណ្តើរៗ។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និង **ឯកឧត្តម ឯកអគ្គរដ្ឋទូត** បានកត់សម្គាល់ដោយពេញចិត្ត ចំពោះការកើនឡើងនូវទំនាក់ទំនងជាមិត្តភាពរវាងប្រទេសទាំងពីរ តាមរយៈការផ្លាស់ប្តូរទស្សនកិច្ចកម្រិតខ្ពស់របស់ថ្នាក់ដឹកនាំនៃប្រទេសទាំងពីរ និងបានឯកភាពពង្រឹងនិងពង្រីកបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ រួមមាន សេដ្ឋកិច្ច ពាណិជ្ជកម្ម ទេសចរណ៍ អប់រំ និងការពារជាតិ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីការត្រៀមទទួលស្វាគមន៍គម្រោងទស្សនកិច្ចនៅកម្ពុជាក្នុងឆ្នាំនេះរបស់ឯកឧត្តមរដ្ឋមន្ត្រីការបរទេសប៉ាគីស្ថាន ដែលជាឱកាសដ៏សំខាន់សម្រាប់ការលើកស្ទួយថែមទៀតនូវទំនាក់ទំនងរវាងប្រទេសទាំងពីរ។ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ក៏បានលើកពីបំណងចង់បើកស្ថានទូតកម្ពុជាប្រចាំនៅប៉ាគីស្ថាននាពេលអនាគត ហើយបានពិភាក្សាជាមួយឯកឧត្តម ឯកអគ្គរដ្ឋទូត អំពីលទ្ធភាពនៃការផ្លាស់ប្តូរការសម្របសម្រួលរវាងប្រទេសទាំងពីរសម្រាប់គោលដៅនេះ។

ឯកឧត្តមឯកអគ្គរដ្ឋទូត បានគូសបញ្ជាក់អំពីការគាំទ្រដ៏ពេញលេញរបស់រដ្ឋាភិបាលប៉ាគីស្ថាន ចំពោះកម្ពុជា ដើម្បីក្លាយជាអ្នកសង្កេតការណ៍ក្នុងអង្គការកិច្ចសហប្រតិបត្តិការអ៊ីស្លាម (Organisation of Islamic Cooperation-OIC)។

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** និង **ឯកឧត្តម ឯកអគ្គរដ្ឋទូត** ក៏បានផ្លាស់ប្តូរទស្សនៈគ្នាលើបញ្ហាតំបន់ និងអន្តរជាតិ ដែលជាចំណាប់អារម្មណ៍រួមផងដែរ ។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល៕

----------------